## **ការឃុំខ្លួន** (detention)

ការឃុំខ្លួន ត្រូវបានធ្វើឡើង ក្រោយពីការជូនដំណឹងអំពីបទចោទ។ ការឃុំខ្លួន អនុលោមតាមវិធានកំណត់ (the Rules of Detention) ដោយគោរពសេចក្តីថ្លៃថ្នូរ (human dignity) និងគោលការណ៍សន្មត់ថាមិនទាន់មានទោស (presumption of innocence)។ ភាពសម្ងាត់នៃព័ត៌មានទទួលបានក្នុងអំឡុងពេលជាប់ឃុំ ត្រូវតែធានា។

ក្នុងករណីបំពានវិធានឃុំឃាំង ការដាក់វិន័យ ឬប្រើកម្លាំង ត្រូវតែមានកម្រិត។ ពួកគេមានសិទ្ធិទទួលបានការសម្រេចអំពីការបំពានវិធានពន្ធនាគារ។ អ្នកជាប់ឃុំឃាំង មានសិទ្ធិទាក់ទងជាមួយគ្រួសារ មិត្តភ័ក្រ តំណាងស្ថានទូត (ករណីជនបរទេស)។

ពាក់ព័ន្ធនឹងយន្តការត្រួតពិនិត្យ ការចុះអធិការកិច្ចពន្ធនាគារជាទៀងទាត់ដោយមិនប្រកាសជាមុន ត្រូវបានធានា។ រយៈពេលឃុំខ្លួន នឹងត្រូវបានរាប់បញ្ចូលក្នុងរយៈពេលគណនាទោស។ នៅពេលដែលជនជាប់ចោទ ត្រូវបានរកឃើញថា គ្មានពិរុទ្ធភាព គាត់នឹងត្រូវបានដោះលែងពីមន្ទីរឃុំឃាំងភ្លាម។ (Antonio Cassese, the Oxford Companion to International Criminal Justice, 2009, pp. 296-298)។

**ខ្លឹមសារបន្ថែម៖** មុននឹងសម្រេចឃុំខ្លួន ចៅក្រមត្រូវរៀបចំនីតិវិធីពិភាក្សាដេញដោល (adversary hearing) ចូលរួមដោយភាគី ដូចជារដ្ឋអាជ្ញា ដែលជាភាគីស្នើឲ្យឃុំខ្លួនជនត្រូវចោទ ដើម្បីសម្រេចថាឃុំ ឬមិនឃុំខ្លួន។ មិនមែនគ្រប់ការចូលខ្លួនរបស់ជនត្រូវចោទទាំងអស់ ត្រូវបានឃុំខ្លួនទេ។ នោះវាអាស្រ័យទៅលើភាពចាំបាច់ និងមូលដ្ឋាននៃការឃុំខ្លួនមានឬគ្មាន។ ដើម្បីពិភាក្សាដេញដោល អនុលោមតាមវិធានសិទ្ធិមនុស្ស ជនត្រូវចោទ ត្រូវបានផ្តល់ពេលវេលា និងឯកសារ ដើម្បីពិគ្រោះជាមុន មុនមានការពិភាក្សាដេញដោល។